# ១១~រឿង សុតានទន្សាយ

## ( ពាក្យកាព្យបទបណ្ដាកគតិ )

នេះនឹងស្រដីពីសព្វប្រាំនៃហោងណាភេមាន់ អក ខ្លា និងទន្សាយទាំងប្រាំនាក់ ។ គិតគ្នាធ្វើផ្ទះនឹងបានប្រើប្រាស់ទុកដាក់គ្រាន់បានសំណាក់ នឹងបានគិតការតទៅ ។ ខ្លាថាបើច្នោះព្រមគ្នា ចំពោះឥឡូវយើងទៅច្រូតស្បូវរួចហើយសឹមយើងគិតសង់ ។ គិតស្រេចហើយណាបប្អូលគ្នីគ្នាដើរត្រង់ពុំហ៊ានបង្អង់ ពុំបានឈប់ឈរឡើយណា ។ ដើរទៅដល់ព្រៃគយគន់រំពៃព្រឹក្សា ឃើញវាលស្បូវនេះហើយគេហៅស្បូវល្អ ។ដល់បោះជំរំនិយាយគ្នាជុំមាត់កថា នេះស្បូវល្អយើងរកទៅទៀតក្រែងគ្មាន ។ យើងច្រូតរៀងអោយ ទោះក្រទោះងាយគង់បានទៅទៀត ក្រែងគ្មានពុំបានប្រទះស្បូវល្អ ។ គេថា ឥឡូវអោយអ្នកណានៅដាំស្លយើងនឹងទៅរកច្រូតស្បូវរួចមកស៊ីបាយ ។ អកឆ្លាស់ឆ្លើយថាចង់អោយបងខ្លានៅអាយចាំដៃរៀបបាយរៀបស្លដណ្ដាំអោយស្រេច ។ ថាហើយនាំគ្នាដើរម្នីម្នារំពេចដល់ទៅព្រៃស្រេចទន្សាយថាគ្នាយើងអើយ ។ យើងច្រូតនៅនេះទៅឆ្ងាយម្ដេចម្ល៉េះអ្នកអើយស្បូវច្រើនម្ល៉េះហើយនេះឯងហៅស្បូវល្អណាស់ ។

ភេ អក និងមាន់ព្រមគ្នារួសរាន់រហ័សច្រូតស្បូវឆាប់ណាស់ តែមាន់ និងអក នូវភេ ។ រីឯទន្សាយរកកលនាយអាយវេះវេភៀស ប្រាប់ទៅគេថាវ៉ឺអើយ គ្នាឈឺពោះ ។ តែវាធ្វើកលកិច្ចដោយយោបល់វានោះវាថាឈឺពោះ តែវាចង់ទៅមើលខ្លា ។ វាដើរឆ្សៀតឈ្លបតិចៗ លបៗ ម្នីម្នាជួបប្រទះខ្លាលោតចាប់ឯក្ដាន់នោះបាន ។ ក៏ឃើញជាក់មិញរត់ទៅឃ្មាតខ្លាញ់ដោយដានដៃឱបខ្លួនប្រាណ វាធ្វើជាគ្រុនញញ័រ ។ ដៃមួយស្ទាបពោះវាដើរទៅនោះ ទទ័រ ញញីញញ័រ វាធ្វើអោយគេជឿមោោង ។ ភេមាន់អកឃើញនឹងមកអឹងកង ហើយជេររំពងចោរម្ដេចអាព្រងើយ ។ មិនរកច្រូតស្បូវ ម្ដេចអាលេងនៅកន្តើយឱបដៃព្រងើយដើរលេងសព្វព្រៃព្រឹក្សា ។ ទន្សាយឆ្លាស់ឆ្លើយថាឱអ្នកអើយអស់

គ្នាកុំអាលផ្តាសា ចាំខ្ញុំដំណាលប្រាប់អ្នក ។ អ្នកអើយខ្ញុំគ្រុនស្ទើរស្លាប់ប៉ប្រុនញ័រញាក់ពោះ ខ្ញុំឈឺចាប់ដោតឈឺចុកផ្ទៃខ្ញុំផង ។ វាឈឺពោះខ្លាញ់ដូចគេត្របាញ់ណាស់ហោងអាស្សូរខ្ញុំផង ខ្ញុំមិនមានពុតទេណា ។

ភេមាន់ដូចអកឮវាប្រាប់មកសោះសាមិនស្រដីទៅវិញទៅមកឡើយនៃ ។ ច្រូតស្បូវតិចទៅទន្សាយនោះស្រដីថា វ៉ីអើយវ៉ីដល់យើងនឹងទៅល្ងាចណា ។ យើងបានត្រីសាច់សំរាប់សំរេចភោជនាគ្រាន់បរិភោគក្តានោះ មានឬទេអកអើយ ។ ទន្សាយថាបើដោយយាមអញមើលជាត្រើយដល់ទៅល្ងាចហើយប្រាកដជាមានលាភជ័យ ។ ភេមាន់អកខ្លា បើច្នោះលងអាទាយនៃអោយប្រាកដក្រៃឥឡូវនេះលងមើលអា ។ ទន្សាយឆ្លាស់ឆ្លើយថា អោយអ្នកអើយគ្រប់គ្នាដល់យើងទៅណាប្រាកដជាបានសាច់ក្តាន់ ។ បើអញទាយត្រូវប្រាកដច្នោះកូវជាក់ស្បាន់ថា បានសាច់ក្តាន់អស់អ្នកកុំស៊ីឡើយណា៎ ។ ភេមាន់អកខ្មី អើនៃវ៉ីយើងប្រាកដមិនស៊ីណា៎ យើងអោយតែអាស៊ីហោង ។ លុះល្ងាចនាំគ្នាដើរមកម្ទីម្នាត្រសងដល់ដៃហេកយហោងហើយដណ្តឹងទៅបងខ្លា ។ ថានៃអ្នកបងអ្នកបានអ្វីហោងជាអាហារបរិភោគក្តាខ្លះទេឬគ្មានឡើយនៃ ។

ខ្លាឆ្លើយប្រាប់មកថា អញទៅរកក្នុងព្រៃ បានក្តាន់មួយវែយកមកចំអិនហើយណា៎ ។ ទន្សាយស្តាប់ជាក់ថាវើយអស់អ្នកគ្រប់គ្នាមែនដូច្នេះណា ថា ឯងមិនស៊ីឡើយហោង ។ ឥឡូវមែនហើយឯងកុំស៊ីឡើយជាម្តងសាច់នោះឯងហោង អញស៊ីតែនឹងបងខ្លា ។ ភេមាន់អកនោះស្តាប់ហើយទ្រគោះសោះសាជេថា ប៉ែអាជកទងខូចក្រៃលែង ។ ថ្វីបើយើងស៊ី យើងមិនស៊ីជូនឯងអាកុហាកខូចឯង រកតែកំភូតមាយា ។ វីអ្នកទាំងប្រាំបរិភោគហើយនាំគ្នីគ្នាដេក លុះព្រឹកណាហើយមកគិតគ្នាទៀតនៃ ។ ថ្ងៃនេះយើងចង់អោយភេនៅវង់ចាំដៃ យើងទាំងបួននៃនឹងទៅច្រូតពីព្រឹកហោង ។ គិតស្រេចហើយណានាំគ្នាយាត្រាជាម្តងដល់ព្រៃស្បូវហោងច្រូតទ្រហឹងវីវរ ។ ភេនៅចាំដៃទៅមុជចាប់ត្រីខ១ បានឆ្តោមកស្ល វង់ចាំអស់គ្នាច្រូតស្បូវ ។ ទន្សាយនោះណាច្រូតបានតិចវាវេះទៅលបមើលភេកូវឃើញភេចាប់បានឆ្តោជាក់ ។ ឃើញហើយវិលទៅខ្លាអកមាន់នៅភ្នា

ភ្ញាក់អាចោរអប្បលក្ខណ៍អាខូចទៅឯណា ។ ទន្សាយឆ្លាស់ឆ្លើយដូចពីដើមឡើយសោះសាអស់ត្រង់នេះណា ដូចយើងស្រដីមុនហើយ ។ ត្រង់ចេះហោរាដូចពីមុនណាអ្នកអើយពុតមិនបាក់ឡើយ ត្រង់វេះត្រង់វេមិនបាត់ ។ ច្រូតលុះល្ងាចអ្នកចាំដៃ បានម្ហូបចំណីឬទេនោះ ទើបឯភេប្រាប់មកថាបានត្រីឆ្តោ ។ ទន្សាយស្តាប់ជាក់ហើយថាអស់អ្នកកោតហោរាអញរាប់ដៃក៏ឥឡូវប្រាកដមែនណា ។ អស់នេះយើងបានស្រដីមែនមានមកប្រាកដពីដើមណាដំណើរសឹងដូចគ្នាហោង ។ អស់អ្នកទាំងប្រាំស៊ីបាយហើយនាំគ្នាផងដេកដល់ព្រឹកហោងមកគិតនិងគ្នាទៀតនៃ ។ ថ្ងៃនេះយើងអោយមកអកគយនៅដៃ អស់យើងទៅព្រៃទាំងបួននាក់នោះហោងណា ។

គិតហើយលេលាដើរទៅម្ទីម្នាសោះសា ដល់ស្បូវច្រូតណាដល់តិចទន្សាយវេះផ្លាប់ ។ ក្រោយនោះបងអកគាត់ទៅសំកុកចាំចាប់ត្រីប្រា បានខ្ចាប់រួចហើយទើបយកមកស្ល ។ ទន្សាយឆ្មៀតឈ្លបដើរមកលលបដកកមើលជាក់ ហើយក៏លេលាទៅវិញជាម្តង ។ ដំណើរនេះខ្លីដូចយើងស្រដីដើមហោងពុតណាស់កន្លងត្រង់ហោរនោះដូចដើមណា ។ លុះល្ងាចលេលាដើរមកម្ទីម្នាសោះសាដណ្តឹងអកថា អ្នកតែងចាំដៃនោះហោង ។ បងអើយបងអកឥឡូវយើងមកជាម្តងបងបានអ្វីហោងគ្រាន់ស៊ីជាម្ហូបឬទេ ។ អកឆ្លាស់ឆ្លើយប្រាប់ទៅគេឆាប់ៗ ថាទេ ខ្លាចក្រែងតែគេនៅពុំដូចអកនេះហោង ។ ឥឡូវអញបាន់ប្រាមួយមកមានជាម្តងចំអិនហើយហោងទុកអោយអ្នករាល់គ្នា ។ ទន្សាយស្តាប់ជាក់ថាឱអស់អ្នករាល់គ្នា អញទាយនេះណា៎ ថាបានត្រីប្រាស៊ីហោង ដំណើរទន្សាយពុតខូចវាយមាយកន្លង ដូចពីដើមហោងរៀងរាបមកនោះឯងណា៎ ។

ថ្ងៃនេះឯងនៃឲ្យមាន់ចាំដៃនោះហោងយើងទាំងបួនផងទៅរកច្រូតស្បូវហោងណា៎ ។ ច្រូតបន្តិចទៅទន្សាយនោះកូវលេលាវេះបាត់ ហើយណាមកឈ្លបចាំមើលមាន់ហោង ។ រឺឯមាន់នោះគិតថប់ក្នុងពោះកន្លង គេចាំដៃផងគេបានសាច់ស៊ីហោងណា៎ ។ ឥឡូវនេះអញមានតែពងអញជាអាហារបរិភោគ ទុកអោយអស់គេស៊ីផង ។ គិតហើយមាន់ពងធ្លាក់ចេញថ្លាត់ជាម្តងយកមកស្ងោរហោងទុកអោយអស់អ្នករាល់គ្នា ។ ទន្សាយ

ឆ្លៀតឈ្លបប្រួញខ្លួនលលបមើលណា៎ ។ ដំណើរនេះហោងអស់ទាំងអ្នកផងគ្រប់គ្នាដឹងអស់ពុតវាអាខូចកុហកវេះហោង ។ លុះល្ងាចនោះកូវអស់អ្នកច្រូតស្បូវជាម្ដងលេលាមកហោង ដល់ហើយដណ្ដឹងមាន់ថា ។ ថាឱ្យបងមាន់បានធ្វើនោះគ្រាន់ស៊ីជាអាហារភោជនាខ្លះទេ ឬ គ្មានឡើយហោង ។ មាន់ថា អញបានពងស្ងោរនៅក្រានជាម្ដងអ្នកកុំគិតហោងត្រង់ម្ហូបនោះឯងឡើយណា៎ ។ ទន្សាយស្ដាប់ជាក់ថាអោយអស់អ្នកគ្រប់គ្នាហោង អញនុតណា៎ប្រាកដដូចអញថាហោង ។ ដំណើរទន្សាយពុតខូចរាយមាយកន្លងពុំលែងជាម្ដង ដូចយើងស្រដីដើមណា៎ ។ អស់អ្នកទាំងប្រាំស៊ីបាយរួច នាំគ្នីគ្នាទៅរកច្រូតស្បូវអឹងកង ។ ថ្ងៃនេះឯងនៃទន្សាយចាំដៃវិញម្ដងយើងប្អូននាក់ផងនេះទៅច្រូតស្បូវហោងណា៎ ។ គិតស្រេចហើយដើរ ទន្សាយនោះកូវវាថា ទុក្ខក្រៃមហិមាព្រួយចិត្តនឹងខ្លួនពេកក្រៃ ។ នឹងរកអ្វីគ្រាន់ជាភោជនាចំណី សង្វាតចាំដៃរកអ្វីជាម្ហូបគ្មានឡើយ ។ ទន្សាយគិតឆ្ងល់នឹកទៅមិនយល់សោះឡើយថា ឱអញអើយអញបានអ្វីជាម្ហូបណា៎ ។ បើដូច្នោះអញល្បងធ្វើតាមទំនងបងខ្លាលបចាប់ក្ដាន់ណាំគ្រាន់បាននឹងយកមកស្ល ។ ទន្សាយគិតដូច្នោះដើរទៅពួនឆ្ពោះធ្វើកលិបជាក់ល្អប៉ុនបំងលបមើលទៅក្ដាន់ ។ ពួនបន្តិចទៅឃើញសត្វនោះកូវជាក់ស្បាន់ពានលើសត្វក្ដាន់ទន្សាយរឹងព្រួយអាត្មា ។ ក្ដាន់ដើរជិតមកទន្សាយចាប់យកសោះសា ក្ដាន់ថាវីធណាទន្សាយនោះដូចផ្កាប់មុខ ។ ទន្សាយដោះឡើងធ្វើមុខស្រមើងពត្រក់មើលមុខអាក្រក់ហើយលាន់មាត់ឯងថា អុះអញម្ដងនេះណាស្លាប់បង់អាសាខ្លួននោះឈឺចាក់ពោះពុងវាខ្លោចវាផ្សាពេកក្រៃ ។ ឆ្អឹងឆ្អែងស្ទើរបាក់ខ្ទាំក្រំញ័រញាក់ណាស់នៃឈឺពោះឈឺផ្ទៃឈឺសព្វសរសៃពេកណា ។ ទន្សាយកំហូចចំណោះបិលប៉ូចខ្លួនវាអាចោរប៉ៃអាខ្លួនប៉ុនកដៃចាប់ក្ដាន់ ។ រួចពីនោះទៅ ទន្សាយនោះកូវកាន់តែគិតរន្ធាន់ព្រួយចិត្តក្រៃងគ្មានម្ហូបស៊ី ។ ទន្សាយនោះកូវធ្វើមុខកញ្ជូវម្នាម៉ីធ្វើត្រាប់ភេខ្វីទៅរកមុជទឹកគយរ ។ មុជដល់ទៅដីលោចាប់បានត្រីសាខរ ត្រីនាំវីវរជ្រមុជទៅយូរពេកក្រៃ ។ ថប់ហើយលែងត្រីស្ទើរដាច់ខ្យល់ឥឡូវនៃភ្នែកនោះសក្រៃ ហាក់ដូចជាមុខខ្មោចណា ។ ឡើងមកក្រញោនធ្វើខ្លួន កំព្រោនដូចស្វាមុខមាត់ជ្រីវណារងាញញ័រជើងដៃ ។

អង្គុយយូរទៅមានកំលាំងកូវហើយនៃព្រួយចិត្តពេកក្រៃ ត្បិតតែមិនបានម្ហូបហោង ។ អស់គេនោះណាគេនៅបានអាហារផង ស៊ីមិនអស់ហោងវាខូចតែអញពេកណា ។ អះបើដូច្នោះ អញនឹកទៅទៀតមិញសោះសា ត្រាប់បងអកណាខ្លាចក្រៃងបានដូចអកធ្វើ ។ គិតដូច្នោះហើយដើរទៅកន្ដើយ រកឈើឡើងសំកុកលើដូចអកនោះឯងហោងណា ។ ត្រីពង្វៀកប្រូងទន្សាយលោតតួងសោះសា ចាប់បានហើយណាត្រីវារត់ទៀតហោង ។ យូរទៅបន្តិចវាថប់ស្ទើរដាច់ខ្យល់ផងលែងត្រីជាម្ដងឡើងទៅអង្គុយមាត់ច្រាំង ។ ភ្នែកវាសល្អក់ មើលមុខអាក្រក់ស្រឡាំងកាំងសម្បុរសស្លាំង ហាក់ដូចជាមុខខ្មោចព្រាយ ។ ហើយរងារញ័រទទីទទ័រអង្គកាយញ័រអស់សព្វផ្សាយរណ្ដំទាំងធ្មេញប៉ប៉ាប់ ។ ឱអញអេញអើយម្ដងនេះមិនស្ទើរស្លាប់បើស្លាប់អោយឆាប់កុំអោយលំបាកច្នេះនៃ ។ ពីនេះតទៅទន្សាយនោះកូវប្រែវៃគិតនៃ បើច្នោះអញត្រាប់មាន់ណា ។ គិតហើយទៅយកឆ្នាំងសម្លមកម្ទីម្ទាយកមកហើយណាទើបរៀបខ្លួនរៀបប្រាណ ។ វាយកឆ្នាំងមកប្រឹងជុះបញ្ច្រាកឆ្នាំង បានកន្លងមែនមានយកទៅចំអិនភោជនា ។ ចំអិនរួចស្រេចហើយ វាក្រឡាច់ម្ទីម្ទាដេកធ្វើដូចជាគ្រុនញាក់ញញីញញ័រ ។ អស់អ្នកច្រូតស្បូវលុះល្ងាចមកកូវទទ័រ ដណ្ដឹងញញ័រថាឱ្យអើយបងទន្សាយ ។

ឯងបានអ្វីជាម្ហូបភោជនាស៊ីបាយរឹងទន្សាយធ្វើជាញ័រមាត់ឆ្លើយវៃ ។ ថាឱអ្នកអើយខ្ញុំនេះគ្រុនហើយណាស់នៃស្ទើរស្លាប់ពេកក្រៃ ខ្ញុំមិនបានម្ហូបអ្វីឡើយ ។ ខ្ញុំខំស្ងោរអាំងប្រហុកនៅឆ្នាំងអ្នកអើយឆ្អិនរួចអស់ហើយចូរអ្នកនាំគ្នាស៊ីហោងអ្នកទាំងប្អូននោះមិនដឹងខ្លួនសោះជាម្ដង ជឿទន្សាយហោងថា ជាប្រហុកមែនណា ។ នាំគ្នាចល់ស៊ីបាយរវល់គ្រប់គ្នា ខ្លះហៅឱ្យអាទន្សាយមកស៊ីឬទេ ។ ទន្សាយឮជាក់ធ្វើជាញ័រញាក់ប្រាប់គេថា ឱមេៗគ្នាគ្រុនស្រៀវណាស់ហោង ។ ចូរអ្នកស៊ីចុះទាំង៤នាក់នោះជាម្ដងកុំចាំអញហោងអញនេះឈឺខ្លាំងណាស់នៃ ។ ភេមាន់អកខ្លាបប្អូលគ្នាឆាប់ក្រៃស៊ីបាយរួចវៃទាល់ឆ្អែតមិនដឹងខ្លួនសោះ ។ រីឯទន្សាយពុតឱលរាយមាយខូចស្មោះគេស៊ីរួចដោះក្រោកឡើងប្រញាប់ដើរផាង ។ ឈរស្ទែតហើយ ទឹមចង្កេះ ញញឹមក្អេងក្អាងថាឱ្យអាឃ្លាង ម្ដេចអា

មកស៊ីអាចម៍អញ ។ ភេមាន់អកខ្លាភ្ញាក់ខ្លួនគ្រប់គ្នាហើយក្តាញ់ជាទុក្ខទោម្នេញគ្រប់គ្នាទីទៃពេកណា ។ ថាវ៉ឺយគ្នាយើងចូរឯងឆាប់ឡើងម៉ីម្នាដេញវាយប៉ែអាចោរខូចចង្រៃដកទង ។ ម្តេចអាកុហកអោយយើងស៊ីលាមកជាម្តង នែវ៉ឺយឆាប់ហោងដេញវាយអាចោរនេះណា ។ថាហើយដេញទៅទន្សាយនោះគូវមិញវាចូលព្រៃព្រឹក្សារកពុំឃើញវាឡើយនៃ ។ ទាំងអស់ គ្នាដេញមិនទាន់វិលវិញវែៗវិលមកឆាប់ក្រែដល់ហើយអង្គុយជុំគ្នា ។

ទន្សាយនោះនៃរត់ ចូលក្នុងព្រៃសោះសា វិលមកវិញណានៅជាមួយគ្នាឯងហោង ។ ភេមាន់ខ្លាអកឃើញទន្សាយមកជាម្តងរសាយខឹងហោង យកវាជាគ្នាវិញណា ។

## បទពំនោល

កាលនោះភេមាន់អកខ្លាទន្សាយនោះណា ច្រូតស្បូវបានសព្វគ្រប់ហោង ។ ហើយមកគិតគ្នាអឹងកង ធ្វើម្តេចរួចហោងដឹកស្បូវទៅផ្ទះយើងណា ។ ទន្សាយវាធ្វើទៅថា មានតែបងខ្លាខ្លួនគាត់នេះធំល្អណាស់ ។គេស្តាប់ទន្សាយឆ្លើយឆ្លាស់ឆ្លើយថាគួរណាស់ខ្លាគាត់មាឌធំល្អជា ។ សមនឹងអួសស្បូវយើងប្រាកដមិនទេណា ខ្លានោះឥតប្រកែកឡើយ ។ ទើបរករៀបផ្ទុកស្បូវហើយឥតមានសល់ឡើយ ដាក់លើខ្នងខ្លានោះនៃ ។ អ្នកខ្លះស្រែកទៅថាវ៉ឺយចានក្បាលខ្ទឹនៅអស់វែកឆ្នាំងនោះណា ។ យកមកដាក់លើខ្នងខ្លាឆាបឡើងម៉ីម្នាហើយយកដែកភ្លើងមកផង ។ រៀបស្រេចហើយមកដាក់ហោងសព្វគ្រប់ហ្មត់ម៉ង ឥតមានភ្លេចអ្វីឡើយណា ។ កាំបិតកាន់គ្រប់គ្នាកណ្តៀវផងវាយកមកសៀតក្នុងស្បូវហោង ។ រៀបស្រេចមកគិតគ្នាកងបាននរណាហោងនឹងជិះលើខ្នងបងខ្លា ។ អកឆ្លាស់ឆ្លើយទៅវិញថាអោយទន្សាយវានោះ វាគ្រាន់ជាអ្នកបរ ។ ទន្សាយនោះស្តាប់ហើយ អកគេអោយអញបរអញខ្ជិលដើរណាស់ហោង ។ ទន្សាយគិតផ្តោះជាម្តងលោតឡើងលើខ្នងខ្លានោះបរទៅឯងនៃ ។ ទន្សាយបរទៅវែៗ ឆ្វាយបន្តិចនៃហើយយកដែកភ្លើងមកវាយ ។ ឮតែច្រិកៗពព្រាយខ្លាសួរទន្សាយថា វ៉ឺយបងទន្សាយហាំ ។ ឮអ្វីច្រិកៗសោះសា ទន្សាយឆ្លើយថាចានវារណ្តំគ្នាវា ។ ខ្លាជឿដើរទៅទៀតណា ទន្សាយនោះវាលួកយកដែកភ្លើងពីខ្នង ។ មកវាយទៀតតែបីដងហើយឆេះជាម្តងប្រឹងផ្លុំអោយឆេះឆាប់ ។ ឆេះហើយវាដាក់ទៅផ្ទាប់ ខាងស្បូវប្រញាប់ភ្លើងនោះផ្តួចឆេះឡើងផង ។ ទន្សាយលោតចេញជាម្តង រត់ខ្ពាញ់ទៅហោងទៅឡើងលើដើមសង្ឃ័រ ។ ផ្សារដោយខ្លួនភិតញញ័រ ឡើងទៅទទ័របេះផ្លែសង្ឃ័រស៊ីហោង ។ ឯខ្លានោះខ្លាំងកន្លង ដល់វាក្តៅខ្នងរលាស់ខ្ទាត់ខ្ទាយចេញណា ។ ឯខ្នងរលាកក្តៅផ្សាចាប់ពើតពេកណា ស្រែកឮលួងទាំងព្រៃ ។ ក្នុងចិត្តខឹងណាស់ពេកក្រៃនឹងទន្សាយ នៃខំរត់ទាំងឈឺតាមទៅ ។ វាស្រែករលួងពេកគូវខំរត់តាមទៅទាន់ទន្សាយនៅសង្ឃ័រ ។ ផ្សាដោយចិត្តខឹងញញ័រទទីទទ័រថា អើអានៅនេះហើយ ។ អញស៊ីក្បាលអាឲ្យស្បើយចិត្ត អញខឹង ហើយឥឡូវនេះឯងហោង ។ អាចោរដកទងប៉ែអាអញរកទេណាឥឡូវអញឃើញហើយនៃ ។ អញចាប់កាច់អោយក្ស័យជីវិតវែៗសឹមអញទំពារលេបណា ។ ទន្សាយស្តាប់ហើយឆ្លើយថា ជេរថាប៉ែអបដកទងចង្រៃចោរលាញ ។ អញ្ជើញអាមកចាប់ទាញអញទៅអម្បាញបើថាខ្លួនអាមិនស្លាប់ ។ ទេពតាលោកចុះមកប្រាប់ឲ្យអញឡើងចាប់បួតស្លឹកសង្ឃ័រស៊ីហោង ។ អញ្ជើញអាមកចាប់លងមិនក្រែងជាម្តង លោកជាទេពតានោះនៃ ។ បើអាមិនមានទុក្ខភ័យលុះដល់ខ្លួនក្ស័យជាងភ្លើងរលាកនោះណា ។ ក្រែងមិនជឿអញលងអាចាប់អញស៊ីជាអាហារអានោះឯងនៃ ។ បើមិនមានទុក្ខភ័យស្លាប់ហើយធ្លាក់ពួនរកធ្ងន់ជ្រៅក្តាត់ណា ។ ខ្លាស្តាប់ទន្សាយចរចាហាក់មែនដូចជាលោមវាម្តងនេះឯងនៃ ។ ក្បិណនោះឯង ខ្លាស្រដីថានៃលេងអ៊ីទន្សាយអញចូលលេងផង ។ ទន្សាយស្តាប់ជាក់ហើយហោងអញនៅជាម្តង អានឹងមកស៊ីអញណា ។ ខ្លាស្តាប់ហើយឆ្លើយទេអាអញហ៊ានស្បថណាកុំអោយព្រះប្រោសអញហោង ។ ទន្សាយជឿខ្លាកន្លងថាបើផ្តោះហោងបងឯងឡើងមកប្រញាប់ ។ បើបងឡើងមកចង់សប្បាយ បងបួតចាប់អំពីគល់ឡើងខ្លាំងក្លា ។

ទន្សាយបង្គាប់នោះណា វាយកបន្លាសង្ឃ័រនោះកោងចុះខ្មី ។ ទើបឯទន្សាយនោះនៃប្រឹងប្រែងជើងដៃលោតចុះទើបខ្លា ឡើងទៅ ។ ទន្សាយរត់ទៅសំពៅ ពានលើ

វល្លិ៍នោះជាទោងល្អក្រៃ ។ ឃើញហើយឡើងឆាប់វៃៗ អង្គុយលើនៃហើយវាយោលជា
ទោងលេង ។ ឯខ្លានោះនៅតែងងឥតកោតឥតក្រែងបួតស្លឹកសង្ស័រលេងហោង ។

ទើបខ្លាក្តាប់ខ្ជាប់ជាម្តង បួតពីដើមហោងវាមុតដៃនោះអស់ណា ។ ចាប់ពើត
បង្កើតឈឺផ្សា លោតចុះដេញអាទន្សាយរត់ខ្ជាញ់ទៀតទៅ ។ ដល់ឃើញទន្សាយនោះ
នៅលើវល្លិ៍នោះគួរថា អាៗនៅនេះហើយ ។ អាបញ្ឆោតអញព្រងើយអាមកកន្តើយនៅ
នេះទេណាអ្នកថ្លៃ ។ អញដើររកអាពេកក្រៃ ឥឡូវនេះនៃប្រទះនឹងអាហើយហោង ។
ទន្សាយស្តាប់ហើយឆ្លើយស្នងជេរវិញរំពងថា អាធ្វើអ្វីអាចម៍អញ ។ ទេពតាទេព្រឹក្ស
ស្រឡាញ់អញណាទើបលោកអោយអញយោលទោងលេង ។ លោកយល់អញចេះ
កំប្លែងលោកអោយអញលេងលោកនឹងទ្រង់ព្រះសណ្តាប់ ។ រីឯខ្លានោះស្តាប់ជាក់ហើយ
ក្រឡាប់រំសាយអស់ខឹងនោះចេញ ។ អង្វរទន្សាយនោះវិញទន្សាយអោយអញយោល
ទោងលេងផងបងភ៉ា ។ ទន្សាយថាអញឆោតណាអានឹងទំពារក្បាលអញឥឡូវនេះឯង ។
ខ្លាថារ៉ុយអើយកុំក្រែង អញស្បថអោយឯងកុំបារម្ភឡើយណា ។ ទន្សាយបានស្តាប់ជឿ
ប្រាកដហើយថាអាឡើងមកយោលលេងចុះហោង ។ អញប្រាប់បងឯងជាម្តងបងមក
យោលលេង យោលអោយខ្លាំងសោះសា ។ នោះទើបអស់លោកទេពតានឹងចូលចិត្ត
ជាស្រឡាញ់បងឯងពេកក្រែង ។ ទន្សាយថា ថ្មោះ រ៉ុយៗចុះមកដល់ដីហើយខ្លាឡើងទៅ
យោលហោង ។ ទន្សាយរត់ខ្ជាញ់ជាម្តងឆ្ងាយក្រៃកន្លងឃើញឬស្សីសង្កៀតគ្នា ។ នេះ
យើងស្រដីឯខ្លាវាយោលទោងណាខ្លាំងៗពេកក្រៃ ។ ដាច់វល្លិ៍ទោងនោះហើយនៃធ្លាក់
មកដល់ដីដូចគេសសុកអស់អង្គ ។ មើលទៅភ្នែកសស្លើតស្លង់ ខំប្រឹងឈរត្រង់កខ្វេសក
ខ្វបសមឹងមាំង ។ យូរបន្តិចមកមានកំលាំងរត់ទៅទាំងផ្សាដោយចិត្តខឹងណាស់ណា ។ រត់
ទៅបន្តិចឃើញអាទន្សាយនោះណានៅលើដើមឬស្សីហោង ។ឃើញហើយថាអាជក
ទង អានៅនេះហោងអាស្លាប់ឥឡូវនេះនៃ ។ ទន្សាយស្តាប់ហើយថាប៉ែអាចោរចង្រៃ
ឃើញអាធ្វើអ្វីអម្បាញ់ ។ ទេពតាទេព្រក្សស្រឡាញ់ទើបលោកអោយអញលេងភ្លេង នៅ
ឯនេះហោង ។ លោកយល់អញចេះកន្លងត្រង់ភ្លេងភ្លាត់ផង នោះទើបលោកអោយ
លេងថ្វាយ ។ ខ្លាស្តាប់ថា ឱម៉ែអាយមែនដឹងអ្នកអាយហាក់ជាពីរោះក្តាត់ណា ។ ខ្លា
លោមទន្សាយហើយថា រ៉ុអើយអោយគ្នាលេងនឹងឯងផងបានទេ ។ ទន្សាយស្តាប់ហើយ
ថាមេអញមិនឆោតទេ ឯងមកនឹងខាំអញនៃ ។ ខ្លាស្តាប់ជាក់លាក់ថាហៃនៃរ៉ុកុំភ័យអញ
មិនចងទោសឡើយណា ។ អញស្បថអោយលោកអ្នកតាកាច់កអញណាឥឡូវនេះឯង
ពិតហោង ។ ទន្សាយស្តាប់ជាក់ជាម្តងបើថ្មោះចូរបងខ្លាឯងឡើងមកចុះណា ។ អញចង់
នឹងផ្តាំខ្លាត្បិតអញនេះណាលេងភ្លេងពីរោះប៉ុណ្ណោះ ។ បើបងមកលេងភ្លេងនេះក្រែង
បងមិនចេះអញប្រាប់បងឯងអោយជាក់ ។

ដល់ខ្យល់បក់មករអាក់យកកន្ទុយដាក់ក្នុងឈើសង្កៀតនោះហោង ។រីឯជាពីរោះ
កន្លង លើសលែងអញហោងទេពតារីងជាស្រឡាញ់ ។ ទន្សាយផ្តាំហើយរត់ខ្ជាញ់ដូចគេ
ត្របាញ់ទៅឆ្ងាយនោះពេកណាស់ហោង ។ ពានលើឱម៉ាល់ធំផង វាដេកថ្ងៃហោងបេះ
យកស្លឹកឈើចុករន្ធ ។ ចុករន្ធស្រេចហើយវាអរលន់យកដៃវាទន់ទះវាយធ្វើភ្លេងជា
ល្បែង ។ ឯរមេឱម៉ាល់នោះឯងផ្អើលក្នុងក្រៃលែង វាចេញមិនរួចសោះសា ។ ពេលនោះ
ទន្សាយនោះវាទះលេងមហិមាឮតែកន្ទ្រប់អ៊ូៗ ។ រីឯខ្លានោះមូទូស្រដីអ៊ូៗធ្វើតែម្នាក់ឯង
ហោងណា ។ ឡើងទៅធ្វើដូចពាក្យអាទន្សាយនោះណាដល់ខ្យល់បក់មកនោះនៃ ។
យកកន្ទុយដាក់វៃៗវាត្បៀតខ្លាំងក្រៃស្រែករោទិ៍រំពងសោះសា ។ ស្ទុះស្ទែងខលខែវតក្ក
មារួចហើយម្នីម្នាលោតចុះដេញទន្សាយទៀត ។ រត់តាមទៅដល់នឹងបៀតឃើញទន្សាយ
ទៀត ហើយស្រែករំពងទៅថា ។ អាចោរនៅនេះហើយណាស្លាប់ម្តងនេះប្រាកដឯង
មិនទេឡើយណា ។ ទន្សាយបែរហើយស្រដីស្លាប់អាចម៍អញនៃធ្វើម្តេចអានឹងបានអញ ។
ទេពតាព្រក្សស្រឡាញ់ ទើបលោកឲ្យអញលេងភ្លេងថ្វាយលោកប្រក្រតី ។ ខ្លាស្តាប់
ហើយឆ្លើយរ៉ុគ្នាលេងផងរ៉ុគ្រាន់បានជាពីរនាក់ណា ។ ទន្សាយស្តាប់ហើយឆ្លើយថា អញ
ឆោតអោយអាមកហើយអានឹងខាំអញ ។ ខ្លាថារ៉ុសំលាញ់ គ្នាមិនថ្មោះមិញនោះគ្នាហ៊ាន
ស្បថនឹងឯង ។ ត្រង់ចិត្តខឹងនោះគ្នាលែងចេញ ហើយកកុំក្រែងរអែងត្រង់នេះឡើយ
ណាំ ។ ទន្សាយជឿហើយៗថា មកចុះបងខ្លាឡើងមកអញផ្តាំបងឯង ។ ដល់បងនឹងវាយ
ជាភ្លេងបងវាយកុំក្រែងរអែងខ្លាចអ្វីឡើយណា ។

ដែលបងធូន់មហិមាវាយអោយខ្លាំងណានោះរឹងជាពីរោះហោង ។ ទន្សាយភិតភ័យកន្លងរត់មើលក្រោយខ្នង ស្រាប់តែធ្លាក់ក្នុងអណ្ដូង ។ ឯខ្លាយកដៃទះផ្ទូងឮតែតូងៗ ធ្លាយសំបុកឪម៉ាល់ណា ។ វារោមចោមខាំមហិមា ខ្លាលោតស្រែកថាម៉ែអើយអញស្លាប់នេះម្ដងហើយ ស្រែកយំកងរំពងខ្លាំងក្រៃពេកហោង ស្ទុះលោតស្ទើរតែមិនទាន់ ។ ចុះមកដល់ដីវាកាន់តែឈរវន្ទាន់ពើតចាប់រមួលមែនមួន ។ ឈឺចាប់ញ័រអស់ទាំងខ្លួនខ្លាំងក្រៃផ្ទួនៗ ពីព្រោះទ្រនិចច្រើនណាស់ ។ លុះស្រាកគ្រាន់បន្ដិចច្បាស់រត់តាមរហ័សទន្សាយនោះទៅទៀតហោង ។ តាមបន្ដិចទៅជាម្ដងឃើញទន្សាយហោងធ្លាក់ក្នុងអណ្ដូងនោះណា ។ ក្រវៀនអៀនប្រៀនឃើញខ្លាមុខដូចខ្មោចណាមមីះក្នុងអណ្ដូងខ្មី ។ ខ្លាឃើញធ្លាក់ហើយស្រដីអានៅនេះវ៉ុ អាស្លាប់ម្ដងនេះឯងណា ។ ទន្សាយថាវ៉ុម៉ែអាគិតឯងអញណាអញនៅក្នុងអណ្ដូងហោង ។ គិតតែអាឯងជាម្ដងនៅលើនោះហោង ក្រែងមេឃរលំសង្កត់ ។ ល្អិតដូចគេមែនភេបត់បាក់ឆ្អឹងខ្ទេចម៉ត់ក្សិណក្ស័យជីវិតមរណាហោង ។ ខ្លាស្ដាប់ហើយភិតកន្លងភ័យណាស់ជាម្ដងលោតចុះក្នុងអណ្ដូងណា ។ ត្រូវជាពីរនាក់នឹងខ្លាទន្សាយនោះណា ក្រវៀនក្នុងអណ្ដូងហោង ។ ទន្សាយគិតឯងជាម្ដងធ្វើម្ដេចអញហោងនឹងបានឡើងទៅលើ ។ ទន្សាយរកកលកិច្ចធ្វើនឹងខ្លាចាក់មើលចង់អោយខ្លាចាប់ចោលទៅ ។ គិតច្នេះយកដៃនោះកួរចាក់ខ្លានោះត្រូវចង្កេះខ្លា លោតបំផ្លោង ។ ខ្លាថាអាចោរគេដោតអាខ្ទូចកញ្ឆោតម្ដេចមិនគិតខ្លួនស្លាប់ ។ បើឥតគំនិតអញចាប់បោះឡើងឆាប់ៗ អោយមេឃរលំស្លាប់ហោង ។ ទន្សាយនឹកអរកន្លងពានចំណុចផង រឹងជាចាក់ណាស់សោះសា ។ ខ្លាខឹងច្រើនដងច្រើនគ្រាអត់ពុំបានណា ក៏ចាប់ទន្សាយចោលប្រូច ។ ទន្សាយថា ឱអញរួចនឹកអរព្រួចៗអញបានរួចពីទុក្ខហោង ។

ទន្សាយស្រែកហៅរំពងអស់អ្នកស្រុកផងអោយមកចាក់ចាប់ខ្លាព្រៃ ។ វាធ្លាក់ក្នុងអណ្ដូងនៃ អ្នកអើយវៃៗ យកដាវលំពែងនិងស្នា ។ ឯផ្ដែកុំយកមកណាយកតែធ្នូស្នាលំពែងកាំភ្លើងនោះហោង ។ ទន្សាយគិតពេកកន្លងកុំយកផ្ដែហោង ។ នោះក្រែងផ្ដែខាំខ្លួនវា ។ ទន្សាយប្រាប់គេហើយណា រួចរត់ទៅប្រាកដឆ្ងាយណាស់ក្រៃពេកហោង ។ រីអស់អ្នកស្រុកអឺងកងហៅគ្នារំពងអោយយកកាំភ្លើងធ្នូស្នា ។ ហើយនាំគ្នាដើរម្ទីម្ទាកាន់គ្រឿងគ្រប់គ្នាចាក់ខ្លានោះស្លាប់ហោង ។

## កំលាំងកាយទុកជាគ្រាន់បើ ក៏មិនស្មើកំលាំងប្រាជ្ញា